# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យចូលឆ្នាំខ្មែរ
# ចំការទៀន ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៩
# ឲ្យយើងថែរក្សាការពារទំនាក់ទំនងអន្តរជំនាន់

**អត្ថបទទី១៖ អេសាយ ៤៩,១-៦**

រីឯខ្ញុំវិញ ខ្ញុំគិតថា ខ្ញុំខំប្រឹងធ្វើការតែបែរជាឥតអំពើ ខ្ញុំខាតកម្លាំងជាអសារបង់ហើយគ្មានបានការអ្វីឡើយ។ ប៉ុន្តែ តាមពិតព្រះអម្ចាស់នៅតែរកយុត្តិធម៌ឲ្យខ្ញុំ ព្រះរបស់ខ្ញុំនឹងប្រទានរង្វាន់មកខ្ញុំ។ អស ៤៩,៤

**ដំណឹងល្អ៖ យ៉ូហាន ១៣,២១-៣.៣៦-៣៨**

កាលព្រះយេស៊ូមានព្រះបន្ទូលដូច្នេះហើយ ព្រះអង្គរន្ធត់ព្រះហឫទ័យក្រៃលែង ទ្រង់មានព្រះបន្ទូលបញ្ជាក់ទៀតថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ក្នុងចំណោមអ្នករាល់គ្នា មានម្នាក់នឹងនាំគេមកចាប់ខ្ញុំ»។ យហ ១៣,២១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងគោរពឆ្នាំថ្មីតាមប្រពៃណីខ្មែរ ឆ្នាំនេះយើងបានចាប់ផ្តើមចូលនៅក្នុងឆ្នាំថ្មីពីថ្ងៃទី១៤ យើងត្រូវនឹករលឹកដល់អំណរសប្បាយរបស់ព្រះសហគមន៍កាតូលិកកម្ពុជាមួយ គឺជាថ្ងៃដែលបានតែងតាំងលោកអភិបាល ឆ្នារ សាឡាស់ ជាអភិបាលដំបូងនៃព្រះសហគមន៍កាតូលិកដែលជាជនជាតិខ្មែរ។ វិសាលវិហារនៅទីក្រុងបារីសបានឆេះយប់មិញ វិសាលវិហារនេះមានអាយុ៨០០ឆ្នាំ ជាវិសាលវិហារដែលគេមកមើលច្រើនជាងគេនៅក្នុងពិភពលោក។ វិសាលវិហារដែលចូលនៅក្នុងទ្រព្យសម្បត្តិស្អាតជាងគេ នៅក្នុងពិភពលោកទាំងមូលកំពុងតែឆេះអស់ហើយ។ រឿងនេះជារឿងសាហាវដែរ ដោយសារវិសាលវិហារបានឆ្លង៨០០ឆ្នាំជាង នៅបារាំងមានសង្គ្រាមមានបដិវត្តន៍នៅឆ្នាំ១៧៨៩ ដែលគេបិទសាសនាកាតូលិកមួយរយៈហើយគេវៃវិហារជាច្រើនចោល ប៉ុន្តែវិសាសវិហារនេះបានស្ថិតនៅរហូតដល់យប់មិញ។

ពេលខ្ញុំនឹកឃើញវិសាលវិហារនៅទីក្រុងបារីស ខ្ញុំនឹកឃើញដល់វិសាលវិហារនៅទីក្រុងភ្នំពេញ ដែលបានចាប់ផ្តើមសាងសង់នៅក្នុងឆ្នាំ១៩៥៥ បញ្ចប់នៅឆ្នាំ១៩៦២ ខ្មែរក្រហមបានវៃចោលនៅឆ្នាំ១៩៧៥។ វិសាលវិហារភ្នំពេញនៅទល់មុខវត្តភ្នំ វិសាលវិហារនេះស្អាតណាស់អ្នកណាក៏មើលនៅក្នុងទីក្រុងភ្នំពេញអ្នកណាក៏ឃើញ។ ប៉ុន្តែពេលខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ការងារទី១របស់ពួកគេគឺវៃចោលវិសាលវិហារហ្នឹង។ ដូច្នេះ ពេលយើងនឹកឃើញព្រះសហគមន៍របស់យើង សព្វថ្ងៃអត់មានវិសាលវិហារទេ មានន័យថាអត់មាន

អាសនៈវិហារ ដែលជានិមិត្តរូបនៃវត្តមានរបស់ព្រះសហគមន៍នៅក្នុងភូមិភាគមួយ។ ភូមិភាគនីមួយៗនៅពិភពលោកមានអាសនៈវិហារមួយ ដែលជាកន្លែងលោកអភិបាលនៅ ជានិមិត្តរូបនៃវត្តមានរបស់ព្រះសហគមន៍កាតូលិក។ យើងអត់មាន ប៉ុន្តែយើងមានព្រះសហគមន៍ និងយើងមានមនុស្សដែលជាគ្រីស្តបរិស័ទ យើងមានបងប្អូនដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងបុណ្យចម្លងខាងមុខនេះ ដែលជាជីវិតនៃព្រះសហគមន៍។ ជនជាតិបារាំងភាគច្រើនគេលែងចូលវិហារយូរហើយ ដូច្នេះពេលគេឃើញវិសាលវិហារគេឆេះ ណែនាំឲ្យគេស្តាយគេយំ ប៉ុន្តែអ្វីដែលជាសំខាន់គឺជំនឿដែលយើងសង្ឃឹមសញ្ញានេះអាចធ្វើឲ្យគ្រីស្តបរិស័ទមួយចំនួននៅទីនោះ ភ្ញាក់ស្មារតីអំពីជំនឿរបស់គេ។ យើងអត់មានវិសាលវិហារ ប៉ុន្តែព្រះសហគមន៍របស់យើងនៅមានជីវិត ព្រះសហគមន៍របស់យើងនៅមានជំនឿ គ្រីស្តបរិស័ទដែលនៅសល់ពីមុនសម័យប៉ុលពត មានប៉ុន្មាននាក់នៅបាត់ដំបង មានប៉ុន្មាននាក់នៅភ្នំពេញ ប៉ុន្តែព្រះសហគមន៍របស់យើងមានជីវិត។ ដោយសារបងប្អូនរបស់យើងយកចិត្តទុកដាក់ ដើម្បីប្រកាសជំនឿ ដើម្បីប្រកាសដំណឹងល្អ និងដើម្បីរស់នៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ដូច្នេះអគារសំខាន់ដែរនេះជាទ្រព្យសម្បត្តិមួយ ប៉ុន្តែសំខាន់គឺយើងធ្វើយ៉ាងម៉េចជាមួយអគារដែលយើងមាន តើយើងប្រើអគារធ្វើជាសារមន្ទីរមួយដើម្បីតែមកមើល ឬទៅជាកន្លែងដើម្បីថ្វាយបង្គំ ទៅជាកន្លែងដើម្បីអធិដ្ឋាន ទៅជាកន្លែងដើម្បីបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់? យើងសង្ឃឹមអំពីព្រះសហគមន៍របស់យើងស្ថិតស្ថេររហូត និងថ្ងៃនេះជាថ្ងៃចូលឆ្នាំថ្មីជាឱកាសមួយដើម្បីជូនពរគ្នា។ ខ្ញុំគិតថាថ្ងៃនេះ ជាពេលវេលាមួយដើម្បីឲ្យយើងសូមព្រះជាម្ចាស់ប្រទានពរឲ្យយើង នេះសំខាន់បំផុតដោយសារពេលឆ្នាំថ្មីយើងជូនពរគ្នាទៅវិញទៅមក ដូច្នេះឲ្យពាក្យជូនពររបស់យើងឆ្នាំនេះមានអត្ថន័យ ពេលយើងទៅផ្ទះ ឬពេលយើងទៅដើរលេងថ្ងៃនេះឲ្យយើងនឹកឃើញទៀតថាខ្ញុំចង់ជូនពរអ្វីខ្លះដល់បងប្អូនខ្ញុំ ដល់ឪពុកម្តាយខ្ញុំ ដល់មិត្តសម្លាញ់ខ្ញុំ ដល់សត្រូវខ្ញុំ? កុំឲ្យយើងជូនពរទូទៅ ឲ្យយើងជូនពរដែលមានអត្ថន័យសម្រាប់មនុស្សម្នាក់ៗ ដោយសារម្នាក់ៗត្រូវការមានជូនពរពីព្រះជាម្ចាស់ ប៉ុន្តែម្នាក់ត្រូវការមានជូនពរពិសេសមួយដែរ។ របៀបព្រះយេស៊ូព្រះអង្គមិនដែលមើលទូទៅព្រះយេស៊ូមើលយើងរៀងៗខ្លួន ព្រះយេស៊ូស្គាល់ឈ្មោះយើង ព្រះយេស៊ូស្គាល់ទម្លាប់យើង ស្គាល់អំពើល្អយើងអំពើអាក្រក់យើង ព្រះយេស៊ូដឹងទាំងអស់ណែនាំឲ្យយើងទទួលកម្លាំងកាយកម្លាំងចិត្ត។ ដូច្នេះថ្ងៃនេះពេលយើងជូនពរកុំឲ្យយើងជូនពរទូទៅ ប៉ុន្តែឲ្យយើងមើលមុខគ្នាទៅវិញទៅមក ជូនពរឲ្យត្រឹមត្រូវឪពុកម្តាយទៅកូន កូនទៅឪពុកម្តាយ កូនទៅលោកតាលោកយាយ ទៅបងប្អូននៅក្នុងក្រុមគ្រួសារ ទៅអ្នកភូមិ ឲ្យយើងជូនពរត្រឹមត្រូវ។ យើងត្រូវការអ្វីខ្លះ គេត្រូវការអ្វីខ្លះឲ្យយើងជូនពរតាមនឹង កុំឲ្យយើងជូនពរអ្វីផ្សេងទៅណាទៅណី។

ខ្ញុំមានជូនពរបីដល់បងប្អូន ជូនពរទី១គឺនៅពេលដែលយើងបានជួបជាមួយអ្នកជម្ងឺអេដស៍នៅមន្ទីរធម្មការនិងសាសនាខេត្តតាកែវ ជាពេលវេលាសំខាន់ដោយយើងបានបង្កើតទំនាក់ទំនងជាមួយបងប្អូន និងនឹករលឹកដល់គុណធម៌មួយដ៏សំខាន់បំផុត គឺជីវិតយើងមានតម្លៃ។ **ឲ្យយើងថែរក្សាអត្ថន័យជីវិតរបស់យើងមានតម្លៃ** ជីវិតរបស់បងប្អូនឯទៀតៗមានតម្លៃ យើងរស់នៅក្នុងសេចក្តីសុខសាន្តបាន លុះត្រាតែយើងចេះស្វាគមន៍គ្នាទៅវិញទៅមកជាមហាគ្រួសាររបស់ព្រះជាម្ចាស់ ដោយសារព្រះជាម្ចាស់បានបង្កើតមនុស្សទាំងអស់ មិនមែនបង្កើតតែយើងជាគ្រីស្តបរិស័ទ។ ឲ្យយើងយកចិត្តទុកដាក់មើលឃើញតម្លៃអត្ថន័យនៃជីវិតរបស់បងប្អូនយើងទាំងអស់ និងឲ្យយើងថែរក្សាការពារតម្លៃនៃជីវិតនោះដោយបង្កើតទំនាក់ទំនងជាគ្រួសារ។ បង្កើតភាតរភាព បង្កើតទំនាក់ទំនងជាបងប្អូន ចេះលើកទឹកចិត្តគ្នាទៅវិញទៅមកជាគ្រួសារតែមួយ។

ជូនពរទី២ ថ្ងៃនេះព្រះសហគមន៍យើងប្លែកពីមុនប្រសិនបើយើងគិតនៅឆ្នាំ២០០២ និង ២០០៣យើងមានតែលោកគ្រូជៀងនិងយុវជន ប៉ុន្តែឥលូវនេះយើងមានយុវជនផង យើងមានប្តីប្រពន្ធផង យើងមានចាស់ៗផង យើងជាព្រះសហគមន៍ចម្រុះ។ បន្តិចទៀតយើងទៅជួបជាមួយលោកតាលោកយាយដើម្បីស្រង់ទឹក **ឲ្យយើងថែរក្សាការពារទំនាក់ទំនងអន្តរជំនាន់** ដើម្បីឲ្យទាំងក្មេងទាំងចាស់ធ្វើដំណើរជាមួយគ្នា ដោយចេះគោរពគ្នាទៅវិញទៅមក។ ក្មេងៗទទួលការអប់រំពីចាស់ៗ ចាស់ៗមើលជីវិតរបស់ក្មេងៗនិងលើកទឹកចិត្តឲ្យទៅមុខ កុំឲ្យចាស់ៗថាក្មេងសម័យនេះវង្វេងអស់ហើយ កុំឲ្យក្មេងៗថាយាយតាលែងយល់គេអស់ហើយ តែឲ្យយើងខិតខំស្តាប់គ្នាទៅវិញទៅមកដោយសារគ្រួសារមួយដែលអត់មានចាស់ជរាដើម្បីប្រៀនប្រដៅ ដើម្បីបង្ហាញផ្លូវ ជាគ្រួសារដែលខ្វះ។ គ្រួសារដែលអត់មានយុវជនយុវនារីពោរពេញដោយកម្លាំង ពោរពេញដោយសេចក្តីសង្ឃឹម ដែលមានគំនិតថ្មីៗជាគ្រួសារដែលខ្វះដែរ។ ដូច្នេះ គ្រួសារដែលជោគជ័យគ្រួសារដែលសុខសាន្តជាគ្រួសារមួយដូចយើងនៅទីនេះ ខ្ញុំជូនពរឲ្យយើងបង្កើតទំនាក់ទំនងអន្តរជំនាន់។

ជូនពរទី៣ នៅសន្តប៉ូលខ្ញុំបាននិយាយទៅនិស្សិត នៅក្នុងឱកាសឆ្នាំថ្មីនេះសម្រាប់យើងទាំងអស់ទាំងបូជាចារ្យ ទាំងលោកអភិបាល ទាំងក្មេងៗ ទាំងឪពុកម្តាយ **យើងធ្វើយ៉ាងម៉េចដើម្បីទទួលខុសត្រូវជាន់ខ្ពស់នៅក្នុងតួនាទីរបស់យើង**។ កុំឲ្យយើងធ្វើល្មមៗ កុំឲ្យយើងស្ទើរ កុំឲ្យយើងខ្វះ ឲ្យយើងទទួលខុសត្រូវជាន់ខ្ពស់នៅក្នុងតួនាទីផ្ទាល់។ ប្រសិនបើយើងទាំងអស់ យើងយកចិត្តទុកដាក់ធ្វើអស់ពីសមត្ថភាព ជីវិតរបស់យើងផ្ទាល់ សង្គមរបស់យើងប្រែប្រួលអស់ហើយ កុំសង្ឃឹមលើគេឲ្យយើងសង្ឃឹមលើខ្លួនឯង។ រៀងៗខ្លួនយើងដឹងចំណុចខ្សោយរបស់យើង យើងដឹងពេលណាយើងខ្ជិល យើងដឹងពេលណាយើងមិនបំពេញតួនាទីរបស់យើងអស់សមត្ថភាព ពេលនោះកម្មវិធីចេញដែរ សកម្មភាពចេញដែរ ស្នាដៃចេញដែរ ប៉ុន្តែវាស្ទើរ។

ដូច្នេះយើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់យើងផ្ទាល់ខ្លួនដើម្បីឲ្យឆ្នាំនេះទៅជាឆ្នាំយ៉ាងពិសេសសម្រាប់ជីវិតរបស់យើង សម្រាប់ព្រះសហគមន៍របស់យើងនិងសម្រាប់ពិភពលោកទាំងមូល។ ជយោឆ្នាំថ្មី! អាម៉ែន៕